+855 (0)61976061
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សាសាបាសាក់ SA SA BASSAC

នៅក្នុងពិព័រណ៍ទោល ខ្លាឃ្លោក របស់ ថន សុខ ដែលមានប្រអប់ពុទ្ធបូជា កាដូ និង ល្បែងស៊ីសង បង្ហាញពី ទម្រង់ សកម្មភាព និង បំណង ចេតនានានាៗជុំវិញការផ្តល់ជូន/អោយ និង ការទទួលយក ដែលវាកើតឡើងនៅក្នុង ដំណើរជីវិតផ្ទាល់ខ្លួនរបស់យើងម្នាក់ៗជារៀងរាល់ថ្ងៃ ទាំងបរិបទសាសនា និង នយោបាយ។

ទាំងចម្លាក់និងគំនូររបស់សិល្បករ បង្ហាញនិងលាក់កំបាំងនូវ គំនិតនិងរូបិយប័ណ្ណភាពនៃការផ្តល់អោយ ក្នុងទម្រង់នៃការផ្តោះប្តូរ ដែលទាំងនេះជាការអនុវត្តស្នាដៃសិល្បៈរបស់សិល្បករមួយបែបក្នុងការប្រៀបប្រដូចរវាង គោលការណ៍នៃការសាងផលបុណ្យរបស់ពុទ្ធសាសនិក និង ផលកម្មល្អដែលទទួលបានមកនៅជាតិខាងមុខ។ នៅក្នុងពុទ្ធសាសនាថេរវាទ កម្មផលល្អដែលទទួលបានពីការធ្វើបុណ្យទាន មិនមែនអាស្រ័យតែទៅលើ បរិមាណគុណភាពផ្នែកព្រលឹងវិញ្ញាណរបស់អ្នកធ្វើ/អោយ និង អាកប្បកិរិយារបស់អ្នកទទួលប៉ុណ្ណោះទេ តែវាក៏អា-ស្រ័យលើរបៀបរបបនៃការអោយ/ជូន និង ចរិកលក្ខណៈរបស់វត្ថុដែលត្រូវបានគេអោយផងដែរ។ ពិព័រណ៍ចំណងជើង ខ្លាឃ្លោករបស់ សុខ បង្ហាញតាមរយៈល្បែងខ្លាឃ្លោកនេះតែម្តងពីការមិនយល់ស្របនូវអ្វីដែលគាត់មើលឃើញ មានដូចជាការកើនឡើងនូវទំនាក់ទំនងបែបស៊ីសំណូក អំណោយ/កាដូបែបមូលធននិយម ព្រមទាំង បំណងចង់បានសម្រាប់ជាតិនេះ។

ចំណងជើងពិព័រណ៍ទាំងមូលកម្ចីពីឈ្មោះល្បែងមួយដែលជាទូទៅគេលេងនៅក្នុងពេលសម្រាក រឺ ពិធីបុណ្យផ្សេងៗក្នុងប្រទេសកម្ពុជា។ ល្បែងនេះមាន គ្រាប់ខ្លាឃ្លោកបីគ្រាប់ និងមានក្រដាស/ក្រណាត់រូប ដែលមានរូបភាព៦យ៉ាងខុសៗគ្នា មានដូចជា ក្តាម ឃ្លោក បង្កង មាន់ ត្រី ក្តាន់ រឺខ្លា។ ចាញ់ រឺ ត្រូវបានមេសង អាស្រ័យទៅលើថាអ្នកលេងនោះ ដាក់លុយត្រូវនិងរូប ពេលគ្រាប់ខ្លាឃ្លោកបើកចេញមករឺអត់។

សុខ ពង្រីកទំហំ គ្រាប់ខ្លាឃ្លោក ដែលខ្លាឃ្លោកនោះជាចម្លាក់មួយ ដែលចំណងជើងវានិងឈ្មោះវាផ្ទាល់គឺដូចគ្នាតែម្តង។ គាត់ជំនួស រូបភាពខ្លះជាមួយនិងរូប សោរឡាន សោរផ្ទះ ផ្កាកុឡាប កាដូ និងប្រអប់ពុទ្ធបូជា។ យើងអាចមើលឃើញថាមានតាំងពីផ្កាសាមញ្ញៗ រហូតដល់ កាដូថ្លៃៗហ៊ឺហា ដែលមាននៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ។ អ្នកលេងដែលដើរតួជាអ្នកអោយរំពឹងថានឹងទទួលផលបានមកវិញ អ្នកលេងដែលដើរតួជាអ្នកទទួលត្រូវបានក្លាយជាអ្នកជាប់បំណុល ហើយល្បែងនេះក៏បន្តទៅតាមវដ្តរបស់វារហូតទៅ។

សិល្បករ បន្ថែមឧទាហរណ៍ខ្លះៗទៀតតាមរយៈស្នាដៃសិល្បៈឈ្មោះថា កាដូ/អំណោយ ១-៦ ដែលជារូបគំនូរពណ៌ទឹកជាស៊េរី មានរូបប្រអប់កាដូនៅបិទជិតនៅឡើយផ្សេងៗ មានការដាក់តាំងជាមួយនិង រូបប្រអប់ពុទ្ធបូជា និង រូបផ្តិលក្រឡុកខ្លាឃ្លោក។

ប្រអប់ខ្មៅ មានការវិលត្រឡប់ទៅរកសំនួរទាក់ទងនិងបំណងចង់បានវិញសារជាថ្មី។ វាជាការដាក់តាំងប្រអប់ខ្មៅនៅជញ្ជាំងជាជួរដែលភ្ជាប់គ្នាពីមួយទៅមួយជាមួយនិងច្រវ៉ាក់ ខណៈប្រអប់ទាំងអស់នោះតំណាងអោយ ភាពមិនអាចមើលឃើញ និង មិនអាចដឹងបានពីចេតនាចង់បានរបស់មនុស្ស។ ប្រអប់ទាំងនោះ បង្ហាញពីការទទួលស្គាល់ការពិតពី ចំណងដែលចងយើងពាក់ព័ន្ធនិង របៀបនិងវប្បធម៌នៃការផ្តល់អោយ និង ទទួលយក។

In Than Sok's solo exhibition, *Klah Klok*, donation boxes, gifts and games address forms, acts, and intentions around giving and receiving as played out in our everyday personal, religious and political relations.

The artist's sculptures and paintings both depict and disguise concepts and currencies of giving as a form of exchange – a practice the artist likens to the Buddhist principle of merit making and its association with positive karmic return in otherworldly life. In Therevada Buddhism, a meritorious offering's karmic return is dependent not only on the spiritual quality of the giver and attitude of the recipient, but also the manner in which one gives, as well as the nature of the object given. Critical of what he sees as increasingly corrupt relations, capitalistic gifts, and this-worldly intentions, Sok's *Klah Klok* hints at the game.

The exhibition title is borrowed from a common gambling game in Cambodia played by all generations, especially around holidays. A set of three dice and a game board bear six icons: crab, gourd *(klok)*, lobster, rooster, goldfish, and deer, or tiger *(klah)* interchangeably. Players lay their bets atop the icons they hope are face-up when the dice settle. Losses and returns are then dealt accordingly.

Sok scales up the Klah Klok dice in his eponymous sculpture, replacing some of its icons with his own: a car key, house keys, a rose, a wrapped gift, and a Buddhist cash donation box. From a simple flower to increasingly lavish gifts in today's Cambodia, the player who is giving expects returns; the player who is receiving becomes indebted, and the game continues its cycle.

The artist further images his provocation in *The Gift 1-6*, a series of Sok's signature watercolor paintings depicting unopened and impersonal gift boxes installed alongside the Buddhist cash donation box and the bowl-capped plate that hides Klah Klok dice.

*Black Box* returns to the question of intention. A row of uniform matte black boxes line the wall, chained together. While they symbolize the invisibility or unknowability of intentions beyond our own, they acknowledge our bondage to the transactional nature of giving and receiving.

# ខ្លាឃ្លោក
# ដោយ ថន សុខ

# Klah Klok
## by Than Sok

03 October -  30 December, 2017

បញ្ជីស្នាដៃសិល្ប
ខ្លាឃ្លោក ដោយ ថន សុខ

ខ្លាឃ្លោក, ឆ្នាំ ២០១៧
បន្ទះដែក, ពណ៌ប្រេង, ថ្នាំរលោង
៨0 សម ការ៉េ, ៣ ប្រអប់
អេឌីហ្សិន ទី១/៣

ប្រអប់ខ្មៅ, ឆ្នាំ ២០១៧
ក្តារ កុងផ្លាកេ, ថ្នាំលាប អេណាមល, ច្រវាក់ដែក
២0 សម ការ៉េ, ១៦ ប្រអប់
អេឌីហ្សិន ទី១/៣

កាដូ/អំណោយ ១-៦, ឆ្នាំ ២០១៧
ពណ៌ទឹក នៅលើក្រដាសគ្មានជាតិអាស៊ីត

៤0 x ៥0 សម

អេឌីហ្សិនពិសេស ដោយ ថន សុខ
ក្រដាស ខ្លាឃ្លោក, ប្រភេទទី ១, ឆ្នាំ ២០១៧
ទឹកថ្នាំ EPSON នៅលើក្រដាស ១៨0 ក្រាម
៤២ x ២៩.៥ សម
ចំនួន ១0 សន្លឹក, មាន លេខរៀង និង ហត្ថលេខា

១00 ដុល្លារ

List of Works

*Klah Klok* by Than Sok

*Klah Klok*, 2017
Aluminum, oil paint, varnish
80cm square, 3 pieces
Edition 3

*Black Box*, 2017
Fiberboard, enamel, metal chain
20cm square, 16 pieces
Edition of 3

*The Gift* 1-6, 2017
Watercolor on acid free watercolor paper
40 x 50 cm
Unique

Special edition by Than Sok
*Klah Klok Game Board, Proposal 1*, 2017
EPSON ink on 180g wood free paper
42 x 29.5 cm
Edition of 10